# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅព្រះសហគមន៍ព្រៃត្រែងកន្ទីវខង់
# ថ្ងៃទី០៩ កក្កដា ២០១៧

អត្ថបទទី១៖សក ៩,៩-១០
អត្ថបទទី២៖រម ៨,៩.១១-១៣
ដំណឹងល្អ៖មថ ១១,២៥-៣០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្ដាប់អត្ថបទ ទាំងអត្ថបទទីមួយ ទាំងអត្ថបទទីពីរ ទាំងអត្ថបទគម្ពីរដំណឹងល្អ ដែលជួយយើងដើម្បីចូលនៅក្នុងអត្ថសញ្ញាលាបថ្វាស គឺទទួលព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះជាម្ចាស់។ យើងបានស្ដាប់លោកប៉ូលថា "បងប្អូនជាទីស្រឡាញ់! ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ មកសណ្ឋិតនៅក្នុងបងប្អូន បងប្អូនមិនមែននៅខាងលោកិយទៀតទេ គឺនៅខាងព្រះវិញ្ញាណ"។ មានន័យថា អ្នកណា គ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ដអ្នកនោះមិនមែនជាកូនចៅរបស់ព្រះអង្គទេ។ បងប្អូនដែលនឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធមានន័យថា ពិតមែនយើងជាកូនចៅរបស់ព្រះជាម្ចាស់ ពិតមែនយើងជាបុត្រធីតារបស់ព្រះជាម្ចាស់។ ប៉ុន្តែណែនាំឲ្យយើងទៅជាមនុស្សថ្មី ដោយសារសន្តប៉ូលបាននិយាយថា ប្រសិនបើយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ប្រសិនបើយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធយើងចូលនៅក្នុងជីវិតខាងវិញ្ញាណ យើងចេញពីលោកិយ។ ឲ្យយើងធ្វើយ៉ាងម៉េច ដើម្បីចេញពីលោកិយ? យើងធ្វើការ យើងមានគ្រួសារ យើងរៀន យើងមានបងប្អូន យើងសប្បាយចិត្តជាមួយបងប្អូន យើងឈ្លោះគ្នាផង យើងមានរឿងច្រើនណាស់ដែលណែនាំឲ្យយើងរស់នៅក្នុងលោកិយមែន។ ប៉ុន្តែថ្ងៃនេះយើងស្ដាប់ថា ពេលយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ យើង ចូលទៅក្នុងលោកថ្មីគឺយើងចូលទៅក្នុងផ្លូវវិញ្ញាណនៃជីវិត ហើយថ្ងៃនេះយើងមានតែបងស្រីសុភី ដែលយើងអាចនិយាយបានថាចេញពីលោកីយហើយ។ តាមពិតយើងជាគ្រីស្តបរិស័ទ យើងគឺជាមនុស្សថ្មីភ្ជាប់ជាមួយព្រះយេស៊ូ។ នេះជាអត្ថន័យដែលព្រះយេស៊ូចង់បង្រៀនយើងថ្ងៃនេះ។ ប៉ុន្តែពេលយើងស្ដាប់គម្ពីរដំណឹងល្អ យើងបានស្ដាប់ថែមទៀតយើងបានស្ដាប់ថា អាថ៌កំបាំងមកពីព្រះជាម្ចាស់ អាថ៌កំបាំងជីវិតខាងវិញ្ញាណ លែងជាអាថ៌កំបាំងសម្រាប់មនុស្សតូចតាច កុំគិតថាយើងចូលសាសនាយេស៊ូ យើងត្រូវការមានចំណេះដឹងខ្ពស់ យើងចូលសាសនាព្រះគ្រីស្ត យើងត្រូវការមានទេវៈវិទ្យាយ៉ាងពិសេស យើងត្រូវ

ការយល់យ៉ាងពិសេស ថ្ងៃនេះយើងបានស្តាប់ច្បាស់ "**ខ្ញុំបានយាងមក ដើម្បីឲ្យមនុស្សតូចតាច យល់ដឹងអំពីជីវិតខាងវិញ្ញាណយល់ដឹងអំពីអ្វីដែលព្រះយេស៊ូចង់ប្រទានឲ្យយើង**"។

ដូច្នេះថ្ងៃនេះជាថ្ងៃពិសេស ដោយសារតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ យើងជាមនុស្សថ្មី ដែលមានកម្លាំងថ្មី ដែលមានសេចក្តីស្រឡាញ់ថ្មី ដែលមានសមត្ថភាពដើម្បីចូលរួមក្នុងសង្គមតាមរបៀបថ្មីដែរ។ ដោយសារព្រះយេស៊ូមានព្រះបន្ទូលថា "**យើងមិនមកពីលោកិយ៍ ប៉ុន្តែយើងរស់នៅក្នុងលោកិយ៍**។ ពិតមែន យើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែយើងរស់នៅក្នុងលោកិយ៍ យើង រស់នៅក្នុងសង្គមបច្ចុប្បន្ននេះ និងព្រះសហគមន៍របស់យើង មិនដែលឡែកពីសង្គមបច្ចុប្បន្ននេះ និងបងប្អូនគ្រីស្តបរិស័ទអត់មានជីវិតពីរ យើងមានជីវិតតែមួយ។ ជីវិតតែមួយ មានន័យថាយើងចូលទៅក្នុងព្រះវិហារ និងយើងរស់នៅក្នុងសង្គម យើងជាគ្រីស្តបរិស័ទដូចគ្នា។ យើងមិនអាចជាគ្រីស្តបរិស័ទ នៅពេលដែលចូលព្រះវិហារតែប៉ុណ្ណឹង! នៅពេលដែលយើងនៅជាមួយបងប្អូនយើង និងទៅផ្សារ ទៅសាលា ឬកន្លែងធ្វើការ យើងភ្លេចរឿងព្រះយេស៊ូអស់ហើយ យើងមិនអាចចែកជាពីរទេ។ យើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ យើងរស់នៅក្នុងព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ប៉ុន្តែណែនាំឲ្យយើងទៅជាគ្រីស្តបរិស័ទសាមញ្ញធម្មតានៅក្នុងលោកិយ៍នេះ។

ខ្ញុំចង់ឲ្យយើងចាំចំនុចពីរនៅថ្ងៃនេះ ដើម្បីឲ្យយើងថែរក្សាជីវិតរបស់យើង សម្រាប់បងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាស ប៉ុន្តែបីដូចជាសម្រាប់បងប្អូនដែលកំពុងឈ្វេងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ **ទីមួយ** ដើម្បីថែរក្សាជីវិតតាមលោកិយ៍ ខ្ញុំអញ្ជើញបងប្អូនឲ្យចិញ្ចឹមខាងផ្លូវវិញ្ញាណ ចិញ្ចឹមផ្លូវវិញ្ញាណដោយថែរក្សាអធិដ្ឋាន។ នេះសំខាន់ណាស់ បើសិនយើងជាគ្រីស្តបរិស័ទ ដែលមិនអធិដ្ឋាន យើងជាគ្រីស្តបរិស័ទដែលមិនស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ យើងដូចម្តេចដើម្បីឲ្យជីវិតខាងវិញ្ញាណ អាចទទួលរីកចម្រើនបាន បន្តិចម្តងៗកុំឲ្យស្ងិតទាំងអស់ហើយ ដោយសារយើងលែងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ យើងត្រូវការយកពេលដើម្បីអធិដ្ឋាន ព្រះសហគមន៍នីមួយៗដែលរីកចម្រើន ជាព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទដែលអធិដ្ឋាន។ នៅថ្ងៃសៅរ៍ពេលយប់ ជាពេលវេលាដើម្បីឲ្យយើងអធិដ្ឋាន តាំងព្រះកាយ មានបទចម្រៀងខ្លះៗ ស្តាប់ព្រះគម្ពីរខ្លះៗ របៀបតែហ្សេក៏បាន នេះជាពេលវេលាសំខាន់ណាស់។ ជាពេលវេលា ដែលយើងកំពុងកសាងព្រះសហគមន៍របស់យើង យើងមើលមិនឃើញនឹងភ្នែក ក៏ប៉ុន្តែជាពេលវេលាដែលព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះបន្ទូលព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់យើង។ បងប្អូនដែលចេញពីព្រះសហគមន៍នេះ ទៅធ្វើការតាមកន្លែងផ្សេងៗ កុំភ្លេចរកកន្លែងដើម្បីជួបជុំគ្នា ដើម្បីចូលព្រះវិហារ។ យើងមានព្រះវិហារជាកន្លែងមួយដែលយើងចូល ប៉ុន្តែមានព្រះវិហារមួយទៀត និងរៀងៗខ្លួនមាន គឺនៅក្នុងដួងចិត្តរបស់យើង យើងមានកូនវិហារមួយ យើងអាចចូលជារៀងរាល់ថ្ងៃ ទោះបីយើងអត់មានអាគារជាព្រះវិហារ យើងអត់មានពេលសម្រាប់ទៅព្រះវិហារនៅភ្នំពេញ។ ប៉ុន្តែ ទោះបី យើងដឹងថាយើងអត់មានអាគារព្រះវិហារមួយដើម្បីចូល រៀងៗខ្លួនមានកូនវិហារមួយនៅក្នុងខ្លួនយើង និងវិហារតូចនេះយើងអាចចូលនៅគ្រប់ពេលវេលាដែលយើងចង់ចូល។ យើងដឹងថា នៅក្នុងវិហារតូចនេះមានព្រះយេស៊ូគង់នៅជានិច្ច ទន្ទឹងរង់ចាំយើងជានិច្ច។ ដូច្នេះកុំស្តាយថាយើងគ្មានកន្លែងចូល យើងដឹងហើយថាមានកន្លែងនេះឲ្យចូលទៅ! សូត្រផ្គាំ សូត្រធម៌ព្រះបិតា បពិតព្រះនាងម៉ារី នឹកឃើញដល់អនុស្សាវរីយ៍ដែលយើងមានព្រះយេស៊ូ។ ចូលទៅ! ព្រះយេស៊ូកំពុងរង់ចាំ នេះជាអ្វីយើងយកចិត្តទុដាក់ ដើម្បីថែរក្សាជីវិតខាងវិញ្ញាណ ធ្វើដូចម្តេចដើម្បីអធិដ្ឋានជារៀងរាល់ថ្ងៃ ដើម្បី ភ្ជាប់ជាមួយព្រះយេស៊ូពិតមែន។ ប្រសិនបើយើងភ្លេចព្រះយេស៊ូ នឹកឃើញយូរៗម្តងបន្តិចម្តងៗយើងនៅឆ្ងាយបន្តិចម្តងៗជីវិតខាងវិញ្ញាណនៅឆ្ងាយ បន្តិចម្តងៗយើងភ្លេចរបៀបអនុវត្តន៍ នេះជាចំនុច**ទីពីរ** ពេលយើងភ្ជាប់ជីវិតខាងវិញ្ញាណនៅខាងក្នុង យើងត្រូវការមើលផ្លែនៅក្នុងជីវិតយើង។ យើងបាននិយាយថាសំខាន់ គឺជំនឿដែលយើងទទួលពីព្រះជាម្ចាស់ ប៉ុន្តែជំនឿនេះណែនាំឲ្យមានផ្លែនៅក្នុងជីវិត។ ផ្លែនៅក្នុងជីវិត គឺ សេចក្តីស្រឡាញ់ដែលយើងចែករំលែកជាមួយបងប្អូនឯទៀតៗ ផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺសេចក្តីស្រឡាញ់ ជំនឿ ការលើកលែងទោស ចិត្តអត់ធ្មត់ ចិត្តបរិសុទ្ធ សេចក្តីសុខសាន្ត។

ដូច្នេះពេលយើងជាប់ជាមួយព្រះវិញ្ញាណ សូមពិចារណា **តើនៅក្នុងជីវិតយើងមានផ្លែឬអត់?** អត្ថបទគម្ពីរអាទិត្យមុន ព្រះយេស៊ូបានលើកឧទាហរណ៍ ដើម្បីសម្តែងធម៌មេត្តាករុណា ព្រះយេស៊ូមានព្រះបន្ទូលថា " **នៅពេលយើងឲ្យទឹកត្រជាក់សូម្បីតែមួយកែវ ឲ្យអ្នកតូចតាចដោយនាមខ្ញុំ យើងជាសាវ័ករបស់ព្រះអង្គ**។ ដូច្នេះពេលព្រះយេស៊ូនិយាយ អំពីសេចក្តីស្រឡាញ់ព្រះអង្គមិនបានលើកឧទាហរណ៍អស្ចារ្យ ដើម្បីសម្តែងធម៌មេត្តាករុណាដល់មនុស្សលោក គឺព្រះអង្គនិយាយស្រួលណាស់ ឲ្យទឹកត្រជាក់មួយកែវដល់អ្នកតូចតាច ដោយនាមព្រះយេស៊ូ។ មានន័យថា យើងយកចិត្តទុកដាក់ជាមួយគេអ្នកតូចតាចដែល

កំពុងមានសេចក្តីត្រូវការ ដើម្បីឲ្យគេសប្បាយចិត្ត គឺយើងធ្វើដោយនាមព្រះយេស៊ូ។ យើងភ្ជាប់នៅក្នុងវិញ្ញាណ យើងធ្វើដូចម្តេចដើម្បីមានផ្លែនៅក្នុងជីវិតរបស់យើង ដោយសារយើងស្រឡាញ់ ដោយសារយើងចង់ធ្វើដូចព្រះយេស៊ូ។ ឧទាហរណ៍ជាក់ស្តែង បងស្រី សុភី សព្វថ្ងៃគាត់ដឹកនាំរោងចក្រកាត់ដេរ ដែលមានគ្នា៥នាក់ដែលធ្វើការ ក្នុងនេះមានស្រីម្នាក់ថ្លង់និងគ ដប់ប្រាំបីឆ្នាំនិយាយមិនបានស្តាប់មិនលឺ ប៉ុន្តែពេលគាត់នៅក្នុងរោងចក្រជាមួយសុភីជិតមួយឆ្នាំពេលខ្ញុំទៅលេងគាត់ គាត់បាននិយាយជម្រាបសួរ នេះជាការអស្ចារ្យមួយដែលកើតឡើងដោយសារបងស្រីសុភីបានយកចិត្តទុកដាក់ជាមួយគាត់ ណែនាំគាត់ឲ្យមានសេចក្តីសុខមានការងារធ្វើ និងប្រហែលអ្វីដែលជាប់នៅក្នុងជីវិតរបស់គាត់ ដប់ប្រាំបីឆ្នាំបានស្រាយអស់ហើយ និងណែនាំឲ្យគាត់និយាយបានស្តាប់លឺ។

ដូច្នេះកុំភ្លេច យើងអធិដ្ឋាន ចិញ្ចឹមវិញ្ញាណ និងយើងដើរបាន យើងគិតរៀងៗខ្លួនដើម្បីធ្វើបាន ដើម្បីឲ្យព្រះសហាគមន៍របស់យើងបន្តមានជីវិត ដោយសារកន្លែងណាដែលយើងនៅគឺយើងនៅដោយនាមព្រះយេស៊ូ ដោយដឹងថាយើងមានព្រះវិហារតូចនៅក្នុងដូងចិត្តយើងជានិច្ច។ ដូចទូរព្រះកាយដែលយើងមាននៅក្នុងព្រះវិហារគិរីវង់នេះ យើងឥតមានភ្លើងខ្ញុំបានគូរព្រះអាទិត្យនៅក្បែរនោះ ដូចគ្នាជាមួយបងប្អូនទាំងអស់គ្នា យើងឥតមានភ្លើងនៅក្នុងខ្លួនប៉ុន្តែយើងទៅជាពន្លឺតូចមួយសម្រាប់មនុស្សឯទៀតៗ ដោយសារយើងមានព្រះវិហារតូចមួយនេះដែលព្រះយេស៊ូគង់នៅ និងព្រះអង្គទៅជាពន្លឺសម្រាប់មនុស្សទាំងឡាយ។ ដូច្នេះពេលគេឃើញយើង គេត្រូវតែភ្លឺដោយសារជីវិតរបស់យើងគឺជាអំពូលតូចមួយ ដើម្បីឲ្យសេចក្តីស្រឡាញ់ទៅគ្រប់ទីកន្លែង។ យើងអធិដ្ឋាន សូមឲ្យព្រះជាម្ចាស់ជួយយើងដើម្បីបង្កើតព្រះសហាគមន៍មួយដ៏វិសុទ្ធ ប៉ុន្តែជាព្រះសហាគមន៍របស់ព្រះយេស៊ូ។ យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើបងប្អូនម្នាក់ៗ ដើម្បីឲ្យជីវិតដែលព្រះយេស៊ូប្រទានឲ្យទៅជាជីវិតសម្រាប់មនុស្សទាំងឡាយ។ អាម៉ែន។